**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

គណៈប្រតិភូរដ្ឋសភាកម្ពុជា ដឹកនាំដោយ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភា និងអមដំណើរដោយ ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ទីប្រឹក្សានិងមន្ត្រីជំនាញនៃរដ្ឋសភា និងមន្ត្រីទូតមកពីស្ថានអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋអាស៊ែបៃហ្សង់ បានចូលរួម «វេទិកាបាគូសកល លើកទី១០» (X Global Baku Forum) ក្រោមមូលបទ «**ពិភពលោកពេលនេះ៖ បញ្ហាប្រឈម និងក្តីសង្ឃឹម**» ពីថ្ងៃទី៧ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២៣ នៅទីក្រុងបាគូ សាធារណរដ្ឋអាស៊ែបៃហ្សង់ ដែលរៀបចំដោយ មជ្ឈមណ្ឌលអន្តរជាតិនីហ្សាមី ហ្គាន់ចាវី (Nizami Ganjavi International Center-NGIC) និងមានការចូលរួមពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល អតីតថ្នាក់ដឹកនាំ និងម្ចាស់ពានរង្វាន់សន្តិភាពណូបែល រួមទាំងតំណាងជាន់ខ្ពស់រដ្ឋាភិបាល សភា អង្គការអន្តរជាតិ និងសង្គមស៊ីវិល ប្រមាណជាង ៣៥០រូប មកពីប្រទេសជាង ៦០។

នៅក្នុងឱកាសនៃការចូលរួមវេទិកានេះ **លោកជំទាវកិត្តិសង្គហបណ្ឌិត** និងគណៈប្រតិភូបានចូលរួមក្នុងពិធីបើកវេទិកាបាគូសកលលើកទី១០ និងជួបសម្តែងការគួរសមជាមួយនឹង ឯកឧត្តម **អ៊ីលហាម អាលីយេវ** (Ilham Aliyev) ប្រធានាធិបតីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ក៏ដូចជាជួបពិភាក្សាការងារជាមួយនឹង ឯកឧត្តម **អាលី អាសាដូវ** (Ali Asadov) នាយករដ្ឋមន្ត្រី និង លោកជំទាវ **សាហ៊ីបា ហ្គាហ្វារ៉ូវ៉ា** (Sahiba Gafarova) ប្រធានរដ្ឋសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ព្រមទាំងចូលរួមជាវាគ្មិននៅក្នុងកិច្ចសន្ទនាស្តីអំពី «**តួនាទីរបស់ចិនលើកិច្ចការសន្តិសុខ និងការអភិវឌ្ឍសកល**»។

នៅក្នុងជំនួបសំដែងការគួរសមជាមួយ ឯកឧត្តម **អ៊ីលហាម អាលីយេវ** ប្រធានាធិបតី **លោកជំទាវកិត្តិសង្គហបណ្ឌិត** បានពាំនាំការសួរសុខទុក្ខនិងក្តីនឹករលឹករបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងការជូនពរចំពោះជោគជ័យនៃវេទិកាបាគូពិភពលោកលើកទី១០។ ជាការឆ្លើយតប ឯកឧត្តមប្រធានាធិបតី បានថ្លែងអរគុណ ចំពោះវត្តមានរបស់លោកជំទាវ និងបានផ្ញើក្តីនឹករលឹក និងសេចក្តីកោតសសើរចំពោះ ភាពជាមេដឹកនាំគម្រូរបស់ សម្តេចតេជោ ប្រកបដោយបទពិសោធន៍ក្នុងការកសាងសន្តិភាព និងការបង្រួបបង្រួមជាតិកម្ពុជា ជាពិសេសការគាំទ្រនិងជំរុញពហុភាគីនិយម ដោយគោរពច្បាប់អន្តរជាតិ និងសូមអបអរសាទរដល់ជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ាន និងប្រជុំពាក់ព័ន្ធកន្លងទៅ។

នៅក្នុងជំនួបពិភាក្សាការងារជាមួយ ឯកឧត្តម **អាលី អាសាដូវ** (Ali Asadov) នាយករដ្ឋមន្ត្រីអាស៊ែបៃហ្សង់ នៅរសៀលថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣ នៅវិមានរដ្ឋាភិបាលអាស៊ែបៃហ្សង់ ភាគីទាំងពីរ បានបង្ហាញពីទស្សនៈវិស័យទំនាក់ទំនងនយោបាយ និងកិច្ចសហប្រតិបត្តិការ ដ៏ល្អរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋអាស៊ែបៃហ្សង់ និងការប្តេជ្ញាចិត្តក្នុងការពង្រឹងទំនាក់ទំនងបន្ថែមទៀត ក្នុងវិស័យនានា រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ វប្បធម៌ និងមនុស្សធម៌ ជាដើម។ ឯកឧត្តមនាយករដ្ឋមន្ត្រី ក៏បានបញ្ជាក់អំពីបំណងមកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងពេលឆាប់ៗខាងមុខនេះ។

នៅក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ លោកជំទាវ **សាហ៊ីបា ហ្គាហ្វារ៉ូវ៉ា** (Sahiba Gafarova) ប្រធានរដ្ឋសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ នៅរសៀលថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ភាគីទាំងពីរបានគូសបញ្ជាក់នូវសមិទ្ធផលជាផ្លែផ្កា ផ្តើមចេញពីដំណើរទស្សនកិច្ចរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ទៅកាន់អាស៊ែបៃហ្សង់ កាលពីឆ្នាំ២០១៤ និងទស្សនកិច្ចរបស់ លោកជំទាវ **សាហ៊ីបា ហ្គាហ្វារ៉ូវ៉ា** ក្នុងឱកាសមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅកម្ពុជា កាលពីខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ ព្រមទាំងជំនួបជាមួយនឹង សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងការចុះអនុស្សរណៈយោគយល់គ្នា រវាងរដ្ឋសភាកម្ពុជា-អាស៊ែបៃហ្សង់។ ភាគីទាំងពីរបាន បញ្ជាក់នូវការប្តេជ្ញាចិត្តក្នុងការបន្តកិច្ចសហប្រតិបត្តិការទ្វេភាគីយ៉ាងជិតស្និទ្ធ ជាពិសេសការគាំទ្រគ្នាទៅវិញ ទៅមកនៅក្នុងវេទិកាអន្តរសភានានា នៅក្នុងតំបន់ និងសកលលោក។

ឆ្លៀតក្នុងឱកាសនេះដែរ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ក៏សូមអបអរសាទរចំពោះសមិទ្ធិផលដ៏គ្រចះគ្រចង់ចំពោះការដឹកនាំរបស់រដ្ឋសភាអាស៊ែបៃហ្សង់ ក្នុងការបង្កើតបណ្តាញសភានៃចលនាមិនចូលបក្សសម្ព័ន្ធ (Non-Aligned Movement – Parliamentary Network, NAM-PN) និងសូមអបអរសាទរចំពោះជោគជ័យនេះការរៀបចំកិច្ចប្រជុំ NAM-PN កាលពីខែកក្កដា ឆ្នាំ២០២២ កន្លងទៅ ដែលសភាកម្ពុជា ក៏បានបញ្ជូនតំណាងជាសមាជិករដ្ឋសភា ២រូប និងសមាជិកព្រឹទ្ធសភា ៣រូប ចូលរួមក្នុងចលនានេះផងដែរ។

**លោកជំទាវកិត្តិសង្គហបណ្ឌិត** ត្រូវបានអញ្ជើញធ្វើជាវាគ្មិន ក្នុងកិច្ចពិភាក្សាស្តីពី «តួនាទីរបស់ចិនលើកិច្ចការ សន្តិសុខ និងការអភិវឌ្ឍសកល»។ នៅក្នុងកិច្ចពិភាក្សា លោកជំទាវ បានគូសបញ្ជាក់ថា ប្រធានបទខាងលើពិតជាមានសារៈសំខាន់ និងទាន់ពេលវេលា ក្នុងខណៈដែលពិភពលោក កំពុងស្ថិតក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកពិភពលោកពហុប៉ូល។ លោកជំទាវ ក៏បានលើកឡើងថា ប្រទេសចិនមានជំហរយ៉ាងច្បាស់លាស់ក្នុងការលើកកម្ពស់ពហុភាគីនិយមមួយដែលពិតប្រាកដ ប្រកបដោយភាពបើកចំហ និងបរិយាបន្ន សម្រាប់សន្តិភាព និងការអភិវឌ្ឍពិភពលោក ហើយកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងចិន និងការកសាងសហគមន៍ជោគវាសនារួម គឺជាគម្រូមួយនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋធំ និងរដ្ឋតូច ដោយឈរលើការគោរពអធិបតេយ្យភាព និងឯករាជ្យភាពគ្នាទៅវិញទៅមក។

**លោកជំទាវកិត្តិសង្គហបណ្ឌិត** និងគណៈប្រតិភូរដ្ឋសភាកម្ពុជា ក៏បានចូលរួម ក្នុងកិច្ចពិភាក្សាក្រោមប្រធានបទសំខាន់ៗ រួមមាន ១) ការកសាងភាពធន់នៅពេលពិភពលោក ដែលកំពុងបែកបាក់ ២) យុគសម័យនៃការគំរាមកំហែងដ៏ធ្ងន់ធ្ងរ ៣) ការបង្កើតឡើងវិញនូវពហុភាពនិយម ៤) ការកសាងនិម្មាបនកម្មសុខភាពពិភពលោកថ្មីមួយ និងកិច្ចពិភាក្សាផ្សេងៗទៀត។

ទស្សនកិច្ចរបស់គណៈប្រតិភូរដ្ឋសភាកម្ពុជា ទៅកាន់ប្រទេសអាស៊ែបៃហ្សង់ បានចូលរួមចំណែកពង្រឹងនិងពង្រីកនូវកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងអាស៊ែបៃហ្សង់ ហើយថែមទាំងចែករំលែកនូវបទពិសោធន៍នៃការកសាងសន្តិភាព លិទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់កម្ពុជាក្នុងការការពារនិងពង្រឹងពហុភាគីនិយម ជាពិសេស ការកសាងមិត្តភាពជាមួយនឹងថ្នាក់ដឹកនាំ នៃបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីកណ្តាល និងអឺរ៉ុបផងដែរ៕

ថ្ងៃចន្ទ ៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣